# លោកុ. ៣៤:៣១-៣៥:១២

**តែគេឆ្លើយថា តើគួរគប្បីដែរឬឱ្យវាមកប្រព្រឹត្តនឹងប្អូនយើងដូចជាស្រីសំផឹងដូច្នេះ (លោកុ. ៣៤:៣១)។**

សំណួរដែលពួកកូនប្រុសយ៉ាកុបទាំងអស់គ្នា សួរនេះត្រឹមត្រូវហើយ។ កូនប្រុសៗទាំងនោះ បានយករឿងដែលកើតឡើងនោះ មកដោះស្រាយដោយកម្លាំងបាយរបស់ខ្លួន ប៉ុន្តែ អ្នកទាំងនោះគួរដឹងឮដែរថា គេមិនមែនគ្រាន់តែរំលោភប្អូនស្រីរបស់ខ្លួនតែប៉ុណ្ណោះទេ គឺគេចង់រៀបការនឹងនាងថែមទៀតផង។ បើប្រសិនណាជាព្រមអនុញ្ញាតអោយប្អូនទៅរៀបការជាមួយនឹងអ្នកដែលរំលោភនាងនោះ ប្រហែលគ្រាន់បើជាងនោះបីការសម្រេចបែបនោះ មិនសូវជាត្រឹមត្រូវពិតប្រាកដក៏ដោយចុះ។ ប៉ុន្តែ ការដែលមិនប្រគល់ប្អូនអោយទៅអ្នកដែលរំលោភប្អូនដើម្បីរៀបការ ហើយបែរទៅជាសម្លាប់មនុស្សទាំងភូមិវិញនោះ វាមិនល្អទាល់តែសោះ។ កិរិយាទាំងពីរនេះ ទោះធ្វើយ៉ាងណាក៏ខុសទាំងអស់។ ការប្រគល់ប្អូនទៅអោយរៀបការជាមួយអ្នកមិនជឿក៏ខុស សម្លាប់មនុស្សទាំងភូមិក៏ខុស ក៏ប៉ុន្តែ ការអោយប្អូនទៅរៀបការជាមួយនឹងសីគែម មានកំហុសស្រាលជាងសម្លាប់មនុស្សរាប់ពាន់នាក់។ កូនប្រុសរបស់យ៉ាកុបទាំងអស់ ពិតជាមិនបានអនុវត្តន៍តាមខ្នាតសីលធម៌ ដែលព្រះជាម្ចាស់បានចែងក្នុងគម្ពីររ៉ូម១២:១៩-២១ យ៉ាងដូច្នេះថា "ឱពួកស្ងួនភ្ងាអើយ កុំឱ្យសងសឹកឡើយ ចូរថយចេញពីសេចក្ដីកំហឹងទៅ ដ្បិត...ការសងសឹកនោះ ស្រេចនឹងអញ អញនឹងសងសឹកដល់គេដូច្នេះ បើសិនណាជាខ្មាំងសត្រូវអ្នកឃ្លាន នោះចូរឱ្យគេបរិភោគចុះ បើគេស្រេកចូរឱ្យផឹកទៅ បើប្រព្រឹត្តដូច្នោះ នោះដូចជាអ្នកបានប្រមូលរងើកភ្លើងដាក់លើក្បាលគេវិញ កុំឱ្យសេចក្ដីអាក្រក់ឈ្នះអ្នកឡើយ ត្រូវឱ្យអ្នកឈ្នះសេចក្ដីអាក្រក់ដោយសារសេចក្ដីល្អវិញ"។

អ្នកគ្រីស្ទានសព្វថ្ងៃនេះ ចាំបាច់ត្រូវតែយកក្បួនច្បាប់ព្រះគម្ពីររ៉ូម១២ មកធ្វើជាមាត្រា ដើម្បីដោះស្រាយទំនាស់ជាមួយគូសត្រូវរបស់ខ្លួន។ នាទីដែលអ្នកគ្រីស្ទានយកការសងសឹកមកធ្វើជាត្រីមុខនាទីនោះ អ្នកគ្រីស្ទានរូបនោះ ឈប់ជឿដល់ព្រះអម្ចាស់ព្រះយេស៊ូវទៀតហើយ។ ពេលដែលគេសងសឹកនោះ គឺគេនិយាយទៅកាន់ព្រះអង្គថា "ខ្ញុំមិនអាចទុកចិត្តព្រះអង្គថា ទ្រង់នឹងរកយុត្តិធម៌អោយខ្ញុំកើតទេ"។ ត្រង់ចំណុចនេះ ខ្ញុំអាចវិនិច្ឆ័យបានថា កូនប្រុសរបស់លោកយ៉ាកុបទាំងអស់ មិនមានការយល់ដឹងខាងព្រលឹងវិញ្ញាណខ្ពង់ខ្ពស់នោះទេ បានជាអ្នកទាំងអស់នោះ នាំគ្នាធ្វើការអាក្រក់ជួរជាតិយ៉ាងដូច្នេះ។ លោកអ្នកយល់ហើយថា ក្តីអាម៉ាស់ដែលកើតឡើងអំពីបុរសម្នាក់មករំលោភកូនស្រីខ្លួននោះ តើមានកំរិតធ្ងន់ធ្ងរត្រឹមណា។ ប៉ុន្តែ លោកអ្នកមិនអាចផ្ទេរការអាម៉ាស់នោះ ទៅសម្លាប់អ្នកស្រុកទាំងភូមិយ៉ាងដូច្នេះឡើយ។ ពេលនេះយើងឃើញថា អ្វីដែលយ៉ាកុបបានសាបព្រោះពីមុនមកនោះ គាត់កំពុងច្រូតផលនោះមកវិញហើយ។ ឯការច្រូតផលនេះ មិនមែនតិចតួចឡើយ គឺបានទាំងញាត់ទាំងរលាក់លើសពីការដែលគាត់ធ្វើដល់គេនោះថែមទៀតផង។

## ជំពូក ៣៥

***ខាងចនា*** *យ៉ាកុបវិលត្រឡប់ទៅបេតអែលវិញ ព្រះអង្គតាំងសញ្ញាសារជាថ្មី នាងរ៉ាជែលស្លាប់ពេលសម្រាលកូនឈ្មោះបេនយ៉ាមីន មរណៈភាពរបស់អ៊ីសាក*

កាលយើងធ្វើការសិក្សានៅក្នុងជំពូក៣៤ ខ្ញុំបានជំរាបលោកអ្នកបងប្អូនថា ជីវិតរបស់យ៉ាងកុបបានផ្លាស់ប្តូរយ៉ាងខ្លាំងនៅពេ្នីអែល។ ប៉ុន្តែ ការផ្លាស់ប្តូរទាំងនោះគ្រាន់តែជាការផ្លាស់ប្តូរមួយកាំដំបូងនៅក្នុងជីវិតរបស់គាត់តែប៉ុណ្ណោះ។ ឯការប្តូរផ្លាស់កាំថែមទៀត មិនទាន់មាននៅឡើយទេ។ ខ្ញុំមិនចង់និយាយថា បទពិសោធន៍របស់យ៉ាកុបនៅពេ្នីអែលរាប់ថាជាវិបត្តិទេ ពីព្រោះមនុស្សភាគច្រើនគេមិនហៅថាជាវិបត្តិ

ឡើយ។ មានពាក្យទំនៀមដែលតែងតែនិយាយកន្លងមកថា បើប្រសិនណាជាមិនធ្វើខុស រកត្រូវមិនឃើញឡើយ។ ប៉ុន្តែរឿងរបស់យ៉ាកុប វាជារឿងផ្សេងអំពីពាក្យទំនៀមនោះ។ យ៉ាកុបមិនមែនប្រព្រឹត្តិកំហុសណាមួយ ដើម្បីអោយគាត់ត្រូវនោះទេ គឺយ៉ាកុបគ្រាន់តែមានការផ្លាស់ប្តូរនៅក្នុងជីវិតរបស់គាត់នៅឯពានីអែលតែប៉ុណ្ណោះ។ តាំងពីថ្ងៃដែលលោកកើតមក ទល់នឹងបទពិសោធន៍នៅភូមិពានីអែលនេះ យ៉ាកុបគ្រប់គ្រងជីវិតខ្លួនគាត់ផ្ទាល់ពោលគឺមានតែគំនិតអាត្មានិយម ពឹងពាក់នៅលើកម្លាំងប្រាជ្ញាខ្លួនឯង។ នៅពានីអែលព្រះជាម្ចាស់កែឆ្នៃយ៉ាកុបអោយជ្រុះកិរិយាអត្តទដ្ឋនិយម ដែលគាត់តែងតែមានតាំងពីក្មេងមក។ បទពិសោធន៍នេះ ប្រៀបឧបមាដូចជា បែកកង់នៅកណ្តាលផ្លូវ ឬក៏ដូចជាប៉េងប៉ោងដែលធ្លាយដោយបុកទង្គិចជាមួយនឹងវត្ថុអ្វីមួយដូច្នោះ។ យ៉ាកុបមិនមានសល់អ្វីទៀតទេ បន្ទាប់ពីគាត់បានជួបបទពិសោធន៍នៅពានីអែល។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ក្នុងជំពូក៣៤ យ៉ាកុបមិនទាន់រៀនដើរនៅក្នុងជំនឿអោយបានពេញលេញពិតប្រាកដនៅឡើយទេ។

ក្រោយពីបងប្រុសរបស់គាត់ឈ្មោះ អេសាវ លាគាត់ត្រឡប់ទៅផ្ទះវិញ យ៉ាកុបបានយកគ្រួសាររបស់គាត់ទៅរៀបចំតាំងទីលំនៅក្បែរទីក្រុងស៊ីគែម។ ការសម្រេចចិត្តនេះខុសធ្ងន់ណាស់។ យ៉ាកុបនៅមិនទាន់បោះបង់ចោលកិរិយាឆ្លាតវាងវៃរបស់គាត់នៅឡើយទេ។ ជាលទ្ធផលកូនស្រីរបស់លោកឈ្មោះឌីណា ត្រូវគេចាប់រំលោភ រួចហើយស៊ីម្មាន និងលេវីដែលត្រូវជាបងប្រុសបង្កើតរបស់នាង បាននាំគ្នាចូលទៅក្នុងទីក្រុងស៊ីគែម ដើម្បីនិយាយជាមួយនឹងស្តេចក្រុងនោះ ឱ្យទទួលខុសលើអំពើអាក្រក់ ដែលកូនប្រុសខ្លួនបានធ្វើ។ ទោះបីស្តេចនោះ មានបំណងល្អចង់រៀបការជាមួយនឹងប្អូនខ្លួនក៏ដោយ ក៏បុរសទាំងពីរនេះ បានសម្លាប់ស្តេចនោះចោលទៅ។ លើសពីនោះទៅទៀតបុរសទាំងពីររូបនេះ ថែមទាំងប្រហារជីវិតមនុស្សជាច្រើននៅក្នុងទីក្រុងទាំងមូលតែម្តង។ នៅពេលដែលបុរសទាំងពីរនាក់នោះត្រឡប់មកដល់ផ្ទះវិញ យ៉ាកុបមិនបានបន្ទោសដល់ អំពើអាក្រក់ដែលកូលលោកទាំងពីរបានធ្វើនោះទេ លោកបែរជានិយាយ

យ៉ាងប្រហើរយ៉ាងដូច្នេះវិញថា "ឯងរាល់គ្នាបានធ្វើអោយអញថប់ព្រួយណាស់ ដោយសំអុយឈ្មោះអញនៅកណ្តាលពួកសាសន៍កាណាននេះ"។

អ្នកបកស្រាយបទគម្ពីរខ្លះបាននិយាយថា បើកុំតែយ៉ាកុបឈប់សំចតនៅក្បែរទីក្រុងស៊ីគែម ម្ល៉េះយ៉ាកុបមិនបានជួបប្រទះជាមួយនឹងរឿងអាក្រក់បែបនោះទេ។ ខ្ញុំយល់ស្របជាមួយនឹងអ្នកបកស្រាយគម្ពីរទាំងនោះខ្លះដែរ ប៉ុន្តែ ខ្ញុំចង់សួរសំណួរពីរយ៉ាងដូច្នេះថា តើយ៉ាកុបមានចំណង់ចង់ទៅនៅបេតអែលដែរឬទេ? តើយ៉ាកុបចង់ជួបជាមួយនឹងព្រះជាម្ចាស់តទៅទៀតដែរឬទេ? ចម្លើយរបស់ខ្ញុំ គឺយ៉ាកុបមិនចង់ទៅបេតអែល ក៏មិនចង់ជួបជាមួយនឹងបទបិសោធន៍ ដែលព្រះជាម្ចាស់សព្វព្រះទ័យអោយទៅគាត់ជួបនោះឡើយ។ អ្វីៗទាំងអស់ដែលកើតឡើងដល់យ៉ាកុបនៅក្នុងជំពូក៣៤ ជាលទ្ធផលដែលយ៉ាកុប ដើរនៅក្នុងកម្លាំងសាច់ឈាមរបស់គាត់ទាំងស្រុង។ នៅក្នុងជំពូក ៣៤ យ៉ាកុបបានជំរុះអាត្មានិយមចោលមែន ប៉ុន្តែ អោយគាត់ឈានទៅដល់ចេះត្រិះរិះពិចារណា ពីជំនឿនៅលើព្រះជាម្ចាស់នោះ គាត់មិនទាន់ចេះនៅឡើយទេ។ ហេតុការណ៍ដែលគាត់ឈប់សំចតនៅក្បែរទីក្រុងស៊ីគែម សបញ្ជាក់អោយយើងឃើញថា គាត់មិនទាន់មានជំនឿគ្រប់គ្រាន់ ដើម្បីនឹងធ្វើដំណើរទៅតាំងទីលំនៅ នៅបេត-អែលឡើយទេ។ ហេតុការណ៍អាក្រក់ដែលកើតឡើងដល់គ្រួសារគាត់ សបញ្ជាក់អោយឃើញថា យ៉ាកុបខ្វះសមត្ថភាពធ្វើជាអ្នកដឹកនាំគ្រួសារខ្លួន។ លោកយ៉ាកុបមិនបានបំពេញតួនាទីរបស់ខ្លួនជាមេគ្រួសារឡើយ។ មិនតែប៉ុណ្ណោះសោតយ៉ាកុបមិនមានសមត្ថភាពដឹកនាំខាងព្រលឹងវិញ្ញាណទាល់តែសោះ។ គាត់មានកូនប្រុសដប់មួយនាក់ ហើយបើគិតមើលទៅ កូនប្រុសទាំងនោះជាហ្វូងយុវជនពាលសុទ្ធសាធ។ យ៉ាកុបមិនបានរៀបចំខ្លួនថា គាត់នឹងត្រូវដឹកនាំដល់យុវជនមួយក្រុមនេះដោយបែបណាទេ។ ប៉ុន្តែ បន្ទាប់ពីពេលដែលលោកជួបជាមួយនឹងហេតុការណ៍អាក្រក់នៅក្នុងជំពូក៣៤នោះមក យ៉ាកុបចាប់ផ្តើមឃើញព្រះហស្តរបស់ព្រះបាន សំយាយមកលើជីវិតរបស់លោក។ ដូច្នេះ

ហើយបានជាលោកសម្រេចចិត្តថា លោកត្រូវធ្វើដំណើរទៅបេតអែល ឯការសម្រេចចិត្តបែបនេះសោត គួរតែធ្វើពីមុនយូរយារណាស់មកហើយ។

## យ៉ាកុបវិលត្រឡប់ទៅបេត-អែល

**រួចមកព្រះទ្រង់មានបន្ទូលនឹងយ៉ាកុបថា ចូររៀបចំឡើងទៅឯ បេតអែល ហើយអាស្រ័យនៅទីនោះចុះ ត្រូវស្អាងអាសនា១ ថ្វាយព្រះដែលបានលេចមកឯឯង ក្នុងកាលដែលឯងរត់ចេញពី អេសាវបងឯង (លោកុ. ៣៥:១)។**

នៅក្នុងពេលច្របូកច្របល់នោះ ព្រះជាម្ចាស់បានត្រាស់ហៅ អោយយ៉ាកុបវិលត្រឡប់ទៅបេតអែលវិញ។ បន្ទាប់ពីទទួលបទពិសោធន៍ដ៏សោកសៅរួចមក ទើបលោករៀបចំចិត្តត្រឡប់ទៅទីកន្លែងដែលព្រះជាម្ចាស់ចង់អោយគាត់ទៅ។ ត្រង់នេះហើយ ដែលខ្ញុំបាននិយាយពីមុនមកថា យ៉ាកុបមិនមានជំនឿគ្រប់គ្រាន់ ដើម្បីនឹងទៅទីនោះទេ ប៉ុន្តែ ពីពេលនេះទៅ គាត់ក៏ចាប់ផ្តើមធ្វើជាអ្នកដឹកនាំខាងព្រលឹងវិញ្ញាណនៅក្នុងគ្រួសាររបស់គាត់ហើយ។

**នោះយ៉ាកុបគាត់ប្រាប់ដល់ពួកគ្រួគាត់ នឹងអស់អ្នកដែលនៅជា មួយថា ចូរចោលព្រះដទៃទាំងប៉ុន្មាន ដែលនៅក្នុងពួកឯងរាល់គ្នាចេញរួចសំអាតខ្លួន ហើយផ្លាស់សំលៀកបំពាក់ឯងចុះ (លោកុ. ៣៥:២)។**

មានមេរៀនល្អៗបីយ៉ាងដែលបង្កប់នៅក្នុងខគម្ពីរមួយនេះ។ មេរៀនទីមួយដែលយ៉ាកុបបង្រៀនដល់គ្រួសាររបស់លោក ក៏ដូចជាបង្រៀនដល់យើងទាំងអស់គ្នាដែរ គឺ "ចូរចោលព្រះដទៃទាំងប៉ុន្មានដែលនៅក្នុងពួកឯងរាល់គ្នាចេញ"។ ពេលឮពាក្យនេះ

យើងទាំងអស់គ្នាហាក់ដូចជាគាំងបេះដូងតែម្តង។ យើងមិនស្មានថា យ៉ាកុបជាមនុស្ស ដែលអាចផ្លាស់ប្រែបានយ៉ាងដូច្នេះឡើយ។ យើងឃើញហើយថា ពេលយ៉ាកុបចាក ចោលផ្ទះសម្បែង លោកឡាបាន់ ជាមួយនឹងប្រពន្ធទាំងពីររបស់គាត់ គឺរ៉ាជែលនិងនាង លេអានោះ នាងរ៉ាជែលបានលួចរូបព្រះចេញពីផ្ទះឪពុកខ្លួន។ នាងយករូបព្រះទាំងនោះ ទៅញាត់ក្នុងកែបសត្វអូដ្ឋ រួចហើយនាងអង្គុយពីលើរូបព្រះទាំងនោះ ពេលធ្វើដំណើរ។ យ៉ាកុបមិនបានដឹងសោះថា ប្រពន្ធរបស់គាត់បានលួចរូបព្រះរបស់ឪពុកក្មេកមកជា មួយទេ។ ពេលដែលឪពុកក្មេកសួរគាត់ថា តើមាននរណាលួចយករូបព្រះមកដែរឬទេ គាត់បានជំរាបឪពុកក្មេកគាត់តាមត្រង់ថា គ្មាននរណាម្នាក់បានយករូបព្រះនោះមកជា មួយឡើយ។ ត្រង់នេះ យ៉ាកុបមានសេចក្តីស្មោះត្រង់ជាមួយនឹងឡាបាន់ ពីព្រោះគាត់មិន បានដឹងថា មានរូបព្រះនៅជាមួយនឹងប្រពន្ធកូនគាត់មែន។

ក្រោយមកទើបគាត់ដឹងថា ប្រពន្ធរបស់គាត់បានលួចរូបព្រះមកជាមួយ។ បើតាមខ្ញុំយល់ ខ្ញុំគិតថា យ៉ាកុបគួរតែប្រាប់អោយប្រពន្ធគាត់បោះចោលរូបព្រះនោះ ចោលតាំងពីយូរយារណាស់មកហើយ ពីព្រោះយ៉ាកុបបានស្គាល់ ព្រមទាំងជួបជាមួយ នឹងព្រះដ៏ពិត នឹងព្រះដ៏រស់ផង។ ទោះបីគាត់បានជួបជាមួយនឹងព្រះជាម្ចាស់ផ្ទាល់ក៏ ដោយ គាត់មិនបានបង្គាប់អោយប្រពន្ធគាត់បោះចង់ចោលរូបព្រះទាំងនោះទេ ពោលគឺ គាត់នៅតែ បណ្តោយអោយសមាជិកគ្រួសាររបស់គាត់ថ្វាយបង្គំរូបព្រះផ្សេងនៅ ឡើយ។ លុះមកដល់ខពីរនេះ ទើបយើងឃើញជាលើកដំបូងហើយថា យ៉ាកុបចាប់ផ្តើម ធ្វើជាមេដឹកនាំខាងព្រលឹងវិញ្ញាណដល់គ្រួសាររបស់គាត់ បានជាគាត់បង្គាប់ដល់គ្រួសារ គាត់ទាំងអស់ថា "ចូរចោលព្រះដទៃទាំងប៉ុន្មាន ដែលនៅក្នុងពួកឯងរាល់គ្នាចេញ"។ ត្រង់ចំណុចនេះ ការដែលគាត់ចង់អោយគ្រួសារគាត់ធ្វើ គឺគ្រប់គ្នាត្រូវបោះបង់ចោល អ្វីទាំងអស់ ដែលខុសជាមួយនឹងព្រះជាម្ចាស់។

មានគ្រីស្ទស័ទច្រើនណាស់ ដែលក្នុងប្រាំមួយថ្ងៃថ្វាយបង្គំរូបព្រះ រួចហើយ នៅថ្ងៃអាទិត្យ គេនាំគ្នាមកថ្វាយបង្គំព្រះដ៏ពិត។ គ្រីស្ទបរិស័ទទាំងនោះ នាំគ្នាថ្វាយបង្គំ

រូបព្រះពីថ្ងៃច័ន្ទដល់ថ្ងៃសៅ រួចហើយពេលមកថ្វាបបង្គំព្រះនៅថ្ងៃអាទិត្យ មុខអោយស្អុយ គ្មានក្តីសប្បាយត្រង់ណាបន្តិចសោះទេ។ កល្យាណមិត្តរៀងរាល់រូបអើយ សូមលោកអ្នកទាំងអស់គ្នាបោះចោលព្រះដ៏ទៃទាំងប៉ុន្មាន ដែលនៅក្នុងគំនិតអ្នករាល់គ្នាចុះ។ ខ្ញុំមិនដឹងថា លោកអ្នកបងប្អូនកំពុងមានរូបព្រះណាមួយនោះទេ ឯរូបព្រះដែលលោកអ្នកកំពុងមាននោះ អាចជារូបព្រះលោភលន់ក៏ថាបាន។ មានអ្នកគ្រីស្ទានដែលរកស៊ីបានចំណេញខ្លះហើយ ក៏ចេះតែធ្វើការអាក្រក់គ្រប់បែបយ៉ាងរកមធ្យោបាយដេញតាមលុយចំណេញឱ្យបានមួយរយ ប្រាំរយ មួយពាន់ រឹតតែច្រើនគ្មានថ្ងៃឈប់ថ្វាយបង្គំព្រះដ៏ពិតទេ គឺគេចេះតែដេញជារៀងរាល់ថ្ងៃ មុខគេងប់ជាមួយតែក្លិននិងសម្លស្សទឹកលុយតែប៉ុណ្ណោះ។ ចំណែកនៅថ្ងៃអាទិត្យវិញ គេមកថ្វាយបង្គំព្រះអង្គយ៉ាងក្រៀមក្រោះដូចបាយកកត្រូវខ្យល់។ លុះយូរៗទៅ គេសួរខ្លួនគេថា ជីវិតខ្ញុំខាងព្រលឹងវិញ្ញាណដូចជាដាច់ឆ្ងាយពីព្រះដល់ហើយ មិនដឹងថាមកពីហេតុអ្វីទេ។ លោកអ្នកបងប្អូនទាំងអស់គ្នាអើយ បើប្រសិនណាជាលោកអ្នកចង់វិលត្រឡប់មកបេតអែលជា "ដំណាក់របស់ព្រះ" ដំបូងឡើយ អ្នកត្រូវបោះបង់ចោលអ្វីដែលខុសជាមួយនឹងបំណងព្រះហឫទ័យរបស់ព្រះជាមុនសិន។

ទីពីរយ៉ាកុបបានបង្គាប់ដល់គ្រួសារលោកថា "រួចសំអាតខ្លួន"។ សំអាតខ្លួនចំពោះពួកអ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទ មានន័យថា លន់តួអំពើបាបរបស់ខ្លួន។ ដើម្បីចូលមកជួបព្រះ លោកអ្នកចាំបាច់ត្រូវជំរះបាប ដែលមាននៅខ្លួនលោកអ្នកផ្ទាល់។ លោកអ្នកមិនអាចគ្រាន់តែចូលវិហារនៅថ្ងៃអាទិត្យ ដោយបំភ្លេចអ្វីៗទាំងអស់ ដែលបានកើតឡើងនៅក្នុងសប្តាហ៍កន្លងទៅនោះទេ។ លោកអ្នកត្រូវចូលមកដំណាក់ព្រះ ដំបូងបង្អស់ត្រូវងូតទឹក ដុះសាប៊ូអោយស្អាត រួចហើយប្រើថ្នាំលាបភ្លៀកដ៏មានក្លិនក្រអូបផងដែរ។ ប៉ុន្តែការជំរះខ្លួនដោយគ្រាន់តែងូតទឹក គ្រាន់តែលាបទឹកអប់ពីលើនោះ មិនគ្រប់គ្រាន់ឡើយ លោកអ្នកត្រូវលន់តួបាបរបស់ខ្លួន ព្រមទាំងសំអាតចិត្តសៅហ្មងទាំងអម្បាលមាណ ដែលអ្នករាល់គ្នាបានប្រព្រឹត្តិទល់មុខព្រះភក្ត្រព្រះជាម្ចាស់ផងដែរ ទើប

សមជាអ្នកចូលមកថ្វាយបង្គំព្រះអង្គនៅឯដំណាក់ទ្រង់។ "បើយើងលន់តួបាបវិញនោះ ទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឱ្យយើង ហើយនឹងសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង" (១យ៉ូហាន១:៩)។ យើងត្រូវលន់តួបាបរបស់យើង ទើបព្រះអង្គអត់ទោសដល់យើងទាំងអស់គ្នា។ ចាំបាច់ណាស់ យើងត្រូវលន់តួបាប ដើម្បីចូលមកដំណាក់របស់ព្រះ។

ឯការទីបី ដែលលោកយ៉ាកុបបង្គាប់អោយអ្នកផ្ទះលោកអោយធ្វើគឺ "ចូរផ្លាស់សំលៀកបំពាក់ឯងចុះ"។ សំលៀកបំពាក់នៅក្នុងបទគម្ពីរសម្តែងអំពីទម្លាប់អាក្រក់។ កាលណាយើងនិយាយអំពីទម្លាប់ យើងសង្កេតមើលអ្នកលេងកីឡាបាល់ទាត់ ឬក៏អ្នកលេងកីឡាផ្សេងៗ គេតែងតែពាក់អាវរបៀបគេលេង ស្លៀកខោរបៀបគេលេង ពាក់មួករបៀបគេលេង ហើយពាក់ស្បែកជើងរបៀបដែលគេលេង ទោះបីគេទៅទីណាក៏ដោយ។ ដូចគ្នាជាមួយនឹងអ្នកលេងកីឡាទាំងនោះដែរ យើងជាកូនរបស់ព្រះគួរមានប្រពៃណីស្លៀកពាក់អោយសមរម្យ មានទម្លាប់អោយត្រឹមត្រូវជាមួយនឹងឋានៈរបស់យើងដែលយើងមានឯកសិទ្ធិធ្វើជាបុត្រធីតារបស់ព្រះដ៏មានព្រះជន្មរស់នៅ។ តើលោកអ្នកពាក់គ្រឿងរបស់ព្រះជាម្ចាស់ ធ្វើជាទម្លាប់របស់យើងរាល់ថ្ងៃដែរឬទេ? តើមនុស្សលោកអាចស្គាល់យើងថា យើងជាកូនព្រះនៅទីផ្សារ នៅសាលារៀន ឬដល់អ្នកដែលនៅក្បែរៗផ្ទះយើងដែរឬទេ? លោកអ្នក ត្រូវពាក់អាវសិរីល្អ គឺអាវដែលសម្តែងពីកោតខ្លាចដល់ព្រះជាម្ចាស់រៀងរាល់វិនាទីនៅក្នុងជីវិតលោកអ្នក។ នៅពេលដែលយ៉ាកុបវិលត្រឡប់ទៅបេតអែលវិញ គាត់ចាប់ផ្តើមជីវិតមួយ ដែលរស់នៅជាមួយព្រះជាម្ចាស់។ តាំងពីមុនមកទល់ពេលនេះ គាត់មិនដែលបានធ្វើយ៉ាងដូច្នេះទេ។ ឥឡូវនេះ គាត់បាននិយាយថា "ចូរយើងវិលត្រឡប់ទៅបេតអែល"។ ដូចជាយ៉ាកុបដែរ យើងត្រូវត្រឡប់ទៅឯបេតអែល គឺជាដំណាក់របស់ព្រះជាម្ចាស់។

**ចូរយើងរៀបចំឡើងទៅឯបេតអែល នៅទីនោះអញនឹងស្អាងអាសនា១ថ្វាយព្រះ ដែលទ្រង់បានឆ្លើយមកអញ ក្នុងកាលដែល អញមានសេចក្តីវេទនា ហើយបានគង់ជាមួយនឹងអញតាមផ្លូវ ដែលអញដើរដំណើរមក (លោកុ.៣៥:៣)។**

លោកអ័ប្រាហាំនិងអ៊ីសាក ក៏បានស្អាងអាសនា រីឯពេលនេះ យ៉ាកុបបានសាងអាសនាដូចជាឪពុក ហើយនិងជីតាលោកបានធ្វើដែរ ដើម្បីអរព្រះគុណដល់ព្រះជាម្ចាស់។ លោកបានធ្វើជាទីបន្ទាល់របស់ព្រះជាម្ចាស់ចំពោះមនុស្សលោកហើយ។

"ទ្រង់បានឆ្លើយមកអញ ក្នុងកាលដែលអញមានសេចក្តីវេទនា ហើយបានគង់ជាមួយនឹងអញតាមផ្លូវដែលអញដើរដំណើរមក"។ យ៉ាកុបនឹកចាំពីកាលគាត់នៅកម្លោះនៅឡើយ គាត់ចាកចេញពីផ្ទះ ហើយគាត់នឹកផ្ទះ គាត់មានភាពឯកកោពេល ដែលគាត់បានមកដល់បេតអែលនេះ ប៉ុន្តែ ព្រះជាម្ចាស់មានភាពស្មោះត្រង់ជាមួយនឹងគាត់ណាស់។ ព្រះជាម្ចាស់មានបន្ទូលទៅកាន់គាត់ថា "អញនឹងរក្សាការស្មោះត្រង់របស់អញ ចំពោះឯងជានិច្ច"។ ជាច្រើនឆ្នាំកន្លងមកជាបន្តបន្ទាប់ ព្រះជាម្ចាស់មានការស្មោះ ត្រង់ជាមួយនឹងយ៉ាកុបពិតប្រាកដមែន។ មកទល់ពេលនេះ ព្រះអង្គមានបន្ទូលមកកាន់ យ៉ាកុបថា "យ៉ាកុប ឯងត្រូវត្រឡប់ទៅឯបេតអែលវិញ។ ឯងត្រូវទៅឯកន្លែងដែលឯង ចាប់ផ្តើម។ ឯកន្លែងចាប់ផ្តើមនោះ គឺនៅឯដំណាក់របស់អញ!"

យើងគ្រប់គ្នាត្រូវតែទទួលស្គាល់ថា យើងបានធ្វើការបង្វែរបង្អង់មិនបានចូលបម្រើព្រះអង្គភ្លាម ក្រោយដែលយើងជឿតាមទ្រង់នោះទេ។ ឯពួកអ៊ីស្រាអែល ក៏ដូចគ្នាដែរ ទ្រង់បានត្រាស់ហៅអោយអ្នកទាំងនោះ ចេញពីប្រទេសអេស៊ីព្ទ ដើម្បីអោយគេចូលទៅទឹកដីសន្យា។ ព្រះជាម្ចាស់បើកសម្តែងអោយគេឃើញ ដើម្បីអោយគេចូលទៅទឹកដីសន្យាកុំបង្វែរបង្អង់ឡើយ។ ផ្ទុយទៅវិញ គេបែរជាបង្វែរបង្អង់នាំគ្នាប្រព្រឹត្តិអំពើអាក្រក់រហូតដល់យឺតយ៉ាវសែសិបឆ្នាំ ដើរវង្វេងឥតប្រយោជន៍ ទាល់តែព្រះជាម្ចាស់មានបន្ទូល

ទៅកាន់យ៉ូស្វេខ្លាំងៗថា "ចូរធ្វើដំណើរទៅទឹកដីនោះចុះ!" យ៉ូស្វេក៏ដូចជាកូនចៅជាតិអ៊ីស្រាអែល នាំគ្នាចំណាយពេលឥតប្រយោជន៍អស់សែសិបឆ្នាំ។ តើគ្រីស្ទានប៉ុន្មាននាក់សព្វថ្ងៃនេះ ដែលចំណាយពេលឥតប្រយោជន៍ មិនព្រមបម្រើព្រះអង្គ? មេរៀនដែលខ្ញុំកំពុងបង្រៀនពេលនេះ គឺសម្រាប់យើងទាំងអស់គ្នាដែលជាកូនព្រះ។ ខ្ញុំមិនដឹងជាបងប្អូនមានលក្ខណៈដូចជាយ៉ាកុប ឬមួយជាយ៉ាងណាទេ ប៉ុន្តែ យើងភាគច្រើនច្រើនតែជាមនុស្សមានលក្ខណៈដូចលោកយ៉ាកុប។ ដូច្នេះហើយ បានជាមេរៀនថ្ងៃនេះលើកឡើងត្រូវជាមួយនឹងយើងទាំងអស់គ្នាណាស់។ យើងអរព្រះគុណព្រះអង្គ ពីព្រោះព្រះអម្ចាស់មានបន្ទូលជារឿយៗថា "ទ្រង់ជាព្រះរបស់យ៉ាកុប"។ ខ្ញុំស្រឡាញ់ឃ្លានេះណាស់! បើព្រះអម្ចាស់ទ្រង់ជាព្រះរបស់យ៉ាកុប ទ្រង់ពិតជាព្រះរបស់យើងទាំងអស់គ្នាដែរ។ ហេតុការណ៍នេះមានភាពអស្ចារ្យខ្លាំងក្រៃណាស់! ជំពូក៣៥នេះ ជាប្រភពនៃការលើកទឹកចិត្តដល់យើងទាំងអស់គ្នា។ ឥឡូវយ៉ាកុបចាប់ផ្ដើមបំពេញតួនាទីជាមេគ្រួសារពិតប្រាកដហើយ។

**នោះគេក៏ប្រគល់ព្រះដទៃទាំងប៉ុន្មានដែលនៅដៃគេ ព្រមទាំង ការទាំងអស់ដែលនៅត្រចៀកគេដល់យ៉ាកុប រួចគាត់កប់ចោល នៅក្រោមដើមម៉ៃសាក់ដែលនៅជិតស៊ីគែម (លោកុ.៣៥:៤)។**

មនុស្សសម័យនោះ កាលណាគេថ្វាយបង្គំអ្វីមួយនៅក្នុងចិត្តគេ គេតែងតែយកវត្ថុនោះមកពាក់ជាប់នឹងត្រចៀករបស់គេ។ ដូច្នេះ ទោះក្រវិល ទោះអាយ៉ាដក់ទាំងអស់ដែលគេពាក់នៅទងត្រចៀកគេនោះ គឺសម្ដែងថា គេជាអ្នកថ្វាយបង្គំរូបអ្វីមួយហើយ។ យ៉ាកុបប្រាប់ដល់ពួកអ្នកផ្ទះរបស់គាត់ថា គេត្រូវតែដោះអ្វីៗទាំងអស់ ចេញពីត្រចៀករបស់គេ "រួចគាត់កប់ចោលនៅក្រោមដើមម៉ៃសាក់ដែលនៅជិតស៊ីគែម"។ យ៉ាកុបបានដោះអ្វីៗទាំងអស់ ដែលទាស់ទទឹងជាមួយនឹងព្រះ រួចហើយយកទៅកប់ចោល ពោល

គឺគាត់មិនមែនគ្រាន់តែយកទៅទុកចោលមួយកន្លែងទេ។ ដើម្បីអោយយើងទាំងអស់គ្នាដើរក្នុងជីវិតថ្មីនៃការជឿដល់ព្រះជាម្ចាស់ យើងត្រូវយកទម្លាប់ចាស់របស់យើងដែលទាស់ទទឹងជាមួយនឹងព្រះជាម្ចាស់ទៅកប់ចោលចេញមិនមែនកប់ទុកទេ!

ទម្លាប់អាក្រក់ដែលទាស់ជាមួយសេចក្ដីបរិសុទ្ធរបស់ព្រះ នោះក៏ជារូបព្រះយ៉ាងធំបំផុតមួយផងដែរ។

**គេក៏ធ្វើដំណើរទៅ ឯគ្រប់ទាំងទីក្រុងនៅជុំវិញទាំងឡាយ ក៏កើតមានសេចក្ដីស្ញែងខ្លាចជាខ្លាំង គេមិនបានដេញតាមពួកកូនយ៉ាកុបទេ យ៉ាកុបនឹងពួកអ្នកទាំងប៉ុន្មាន ដែលនៅជាមួយនឹងគាត់ ក៏ ទៅដល់លូស ដែលនៅក្នុងស្រុកកាណាន គឺជាបេតអែល (លោកុ.៣៥:៥-៦)។**

កន្លែងដែលយ៉ាកុបធ្វើដំណើរទៅដល់នេះ ទូទៅគេហៅថា ភូមិលូសទេ ប៉ុន្តែក្រោយមកយ៉ាកុបបានដូរឈ្មោះភូមិទៅជាបេតអែលវិញ។

**នៅទីនោះគាត់ស្អាងអាសនា១ រួចដាក់ឈ្មោះទីនោះថា អែល-បេត-អែល ដ្បិតគឺនៅទីនោះហើយ ដែលព្រះទ្រង់បានលេចមកឯ គាត់ក្នុងកាលដែលគាត់រត់ពីបងទៅ (លោកុ.៣៥:៧)។**

បេតអែលប្រែថា "ដំណាក់ព្រះ" ហើយយ៉ាកុបដាក់ឈ្មោះនេះ កាលដែលគាត់មកដល់ទីនោះលើកដំបូង។ គាត់ដាក់ឈ្មោះថា អែល-បេត-អែល ដែលប្រែថា "ដំណាក់របស់ព្រះ"។ ចំណុចនេះ យើងឃើញមានការលូតលាស់ខាងព្រលឹងវិញ្ញាណនៅក្នុងខ្លួនរបស់យ៉ាកុបហើយ។ សូមយើងទាំងអស់គ្នា ពិចារណាខគម្ពីរយ៉ាងល្អមួយនេះជាបន្តទៅទៀត។

**គ្រានោះ ដេបូរ៉ាជាមេធំរេបិកាក៏ស្លាប់ហើយគេកប់នាង នៅក្រោមដើមម៉ៃសាក់ខាងក្រោមបេតអែល ដែលគេហៅថា ដើមម៉ៃសាក់ទឹកភ្នែក (លោកុ.៣៥:៨)។**

នាងដេបូរ៉ាជាមេដោះរបស់យ៉ាកុប ហើយត្រូវជាមេធំរបស់រេបិកា។ នាងមកជួបយ៉ាកុប ដើម្បីនាំដំណឹងមកប្រាប់ថា ម្តាយស្លាប់ហើយ រួចហើយយ៉ាកុបក៏អោយគាត់នៅជាមួយនឹងគាត់ រហូតមកដល់ពេលដែលមេដោះគាត់ស្លាប់នៅទីនេះទៅ។ យ៉ាកុបមិនដែលបានឃើញមុខម្តាយគាត់ទេ ឯម្តាយក៏មិនដែលឃើញមុខយ៉ាកុបដែរ គាត់គ្រាន់តែបញ្ជូនកូននោះ អោយទៅនៅជាមួយនឹងបងប្រុសរបស់គាត់ រួចហើយគាត់ក៏ស្លាប់ទៅ។ មកទល់ពេលនេះ នាងដេបូរ៉ា ក៏ស្លាប់ដែរ។

## ព្រះអង្គតាំងសញ្ញាសារជាថ្មី

**កាលយ៉ាកុបបានត្រឡប់មកពីប៉ាដាន់-អើរ៉ាម ហើយនោះ ព្រះទ្រង់លេចមកឯគាត់ម្តងទៀត ព្រមទាំងប្រទានពរដល់គាត់ (លោកុ.៣៥:៩)។**

ជាយូរឆ្នាំមកហើយ ព្រះជាម្ចាស់បានកែឆ្នៃលោកយ៉ាកុប។ ប៉ុន្តែព្រះអង្គមិនទាន់កែឆ្នៃគាត់អោយបានត្រឹមត្រូវភ្លាមៗទេ ទាល់តែដល់ពេលដែលគាត់ត្រឡប់មកដល់ភូមិបេតអែលវិញ ដែលគាត់ធ្លាប់មកសំណាក់ កាលពីគាត់នៅក្មេងនៅឡើយ។ អស់ទាំងឆ្នាំដែលគាត់បានចំណាយពេលនៅជាមួយឪពុកធំរបស់គាត់ឈ្មោះឡាបាន់ គឺជាឆ្នាំដែលចំណាយយ៉ាងឥតប្រយោជន៍ទទេៗ។

**ទ្រង់មានបន្ទូលថា ឯងមានឈ្មោះថា យ៉ាកុប តែមិនត្រូវហៅថា យ៉ាកុប ទៀតទេ គឺត្រូវហៅថា អ៊ីស្រាអែលវិញ ដូច្នេះទ្រង់បាន ដាក់ឈ្មោះថា អ៊ីស្រាអែលឱ្យគាត់ រួចទ្រង់មានបន្ទូលនឹងគាត់ថា អញជាព្រះដ៏មានគ្រប់ ទាំងព្រះចេស្តា ចូរឯងបង្កើតកូនចំរើនជា ច្រើន ឡើង នឹងមានសាសន៍១ គឺសាសន៍ជាច្រើនរួមគ្នាតែ១ កើតពីឯងមក ក៏នឹងមានស្តេចជាច្រើន ចេញពីឯងដែរ (លោកុ. ៣៥: ១០-១១)។**

"អញជាព្រះដ៏មានគ្រប់ទាំងព្រះចេស្តា"។ កាលព្រះជាម្ចាស់មានបន្ទូលទៅ កាន់លោកអ័ប្រាហាំ ព្រះអង្គក៏មានបន្ទូលថា នាមរបស់ព្រះអង្គយ៉ាងដូច្នេះដែរ។

**ឯស្រុកដែលអញបានឱ្យដល់អ័ប្រាហាំ នឹងអ៊ីសាក នោះអញនឹងឱ្យដល់ ឯង គឺអញនឹងឱ្យស្រុកនោះ ដល់ពូជឯងតរៀងទៅ (លោកុ.៣៥: ១២)។**

ទឹកដីដែលព្រះអម្ចាស់បំរុងនឹងអោយទៅដល់ពូជពង្សអ័ប្រាហាំនេះ ជាទឹកដីពិសេសណាស់។ មកទល់ពេលនេះ ជាលើកទីបីហើយ ដែលព្រះអម្ចាស់សន្យាថា អោយទឹកដីនេះ ទៅដល់ពូជពង្សលោក ទីមួយគឺព្រះអង្គសន្យាទៅដល់លោកអ័ប្រាហាំ ទីពីរដល់លោកអ៊ីសាក ឥឡូវនេះជាលើកទីបី គឺទ្រង់សន្យាថាប្រទានដល់លោកយ៉ាកុប។ ព្រះអម្ចាស់មានបន្ទូលសន្យាបែបនេះ តែពីរទៅបីដង ដល់អ៊ីសាក និងយ៉ាកុប ប៉ុន្តែចំពោះលោកអ័ប្រាហាំវិញ ព្រះអង្គមានបន្ទូលបែបនេះទៅកាន់គាត់ជាច្រើនលើក ច្រើនសារ។